# ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ២០៨(**២០២២**) មនុស្សឃាដដោយចេតនា

**ពាក្យគន្លឹះ៖** អនីតិជន ស្ថានសម្រាល នីតិរួមនិងច្បាប់ពិសេស ច្បាប់អនុវត្ត

## ១.អង្គហេតុនិងប្រវត្តិនីតិវិធី

ខែធ្នូ ឆ្នាំ២០១៧ នៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ **ផខស** និងមនុស្ស ២នាក់ទៀត ត្រូវបានចោទថាបានពួនស្ទាក់លើជនរងគ្រោះ **សស**។ អង្គហេតុនេះ ត្រូវបានចោទជាបទឃាតកម្មគិតទុកជាមុន។ សាលាដំបូង បានចេញសាលក្រមលេខ២៦(ខ) ខែឧសភា ឆ្នាំ២០១៩ សម្រេចដាក់ទោស **ផខស** អាយុ១៧ឆ្នាំ និង **នផន** ម្នាក់ៗ ១៥ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន។ ជនជាប់ចោទទាំងពីរមិនសុខចិត្តបានប្ដឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍ចេញសាលដីកាលេខ២៩ ខែឧសភា ឆ្នាំ២០២១ តម្កល់សាលក្រមលេខ ២៦។ ជនជាប់ចោទទាំងពីរ មុនសុខចិត្តបានប្ដឹងសាទុក្ខមកតុលាការកំពូល ដែលបានធ្វើសវនការ និងចេញសាលដីកាលេខ២០៨ ខែឧសភា ឆ្នាំ២០២២ តម្កល់ខ្លះ និងបដិសេធផ្នែកខ្លះ ដោយបង្វិលទៅឲ្យសាលាឧទ្ធរណ៍ពិនិត្យឡើងវិញ លើទោសទណ្ឌពាក់ព័ន្ធអនីតិជនអាយុ១៧ឆ្នាំ (**ផខស**)។

## ២.សំអាងហេតុនិងសេចក្ដីសម្រេច

ក្រោយពីបានពិចារណា តុលាការកំពូលបានយល់ឃើញដូចតទៅ៖ *ការដែល ប្រកាសទោសដល់ជនជាប់ចោទទាំងពីរ ដែលម្នាក់ជាអនីតិជនអាយុ១៧ឆ្នាំ ឲ្យមានទោសស្មើគ្នាជាការពុំត្រឹមត្រូវទេ ...ត្រូវពិចារណាដាច់ដោយឡែកតាមបញ្ញត្តិមាត្រា១៦០ ត្រង់កថាខណ្ឌទី១ចំណុចទី២នៃក្រមព្រហ្មទណ្ឌ។* តុលាការកំពូលរកឃើញថា តាមសំអាងហេតុក្នុងសាលដីកា មានចម្លើយស៊ីសង្វាក់ បង្ហាញថា បានពួនស្ទាក់វាយជនរងគ្រោះបណ្ដាលឲ្យស្លាប់ប្រាកដមែន បង្ហាញដោយភស្តុតាង។

**សម្រេច៖** ២.បដិសេធផ្នែកបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ....តម្កល់សាលដីកាលេខ២៩ ទុកជាបានការ លើកលែងទោសអនុវត្តចំពោះអនីតិជន..៣.បញ្ជូនសំណុំរឿង...ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ត្រង់ចំណុចដែលបានបដិសេធ។

## ៣.កំណត់សំគាល់

១. មាត្រា៤១៩ នៃក្រមនីតិវិធីចែងអំពីមូលហេតុដែលបណ្ដឹងសាទុក្ខ អាចត្រូវបានទទួលយកមកពិចារណាដោយតុលាការកំពូល ដូចជា ការបំពានអំណាច ឬការអនុវត្តច្បាប់ខុស។ សាលដីកានេះ មិនបានពន្យល់អត្ថន័យនៃពាក្យទាំងនេះទេ ក៏ប៉ុន្តែគេអាចយល់បានថា ការដែលសាលាឧទ្ធរណ៍ មិនប្រើមាត្រា ១៦០(១)ចំពោះអនីតិជន ជាការអនុវត្តច្បាប់ខុស ដែលបណ្ដឹងសាទុក្ខអាចទទួលយកបាន។

**២**. តាមមាត្រា១៦០(១) អនីតិជនអាយុក្រោម១៨ឆ្នាំនឹងទទួលបានការបន្ថយទោសដោយស្វ័យប្រវត្តិ (១- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល)។ កន្លងមក ជាការអនុវត្ត ក្នុងសំណុំរឿងមួយ ប្រសិនបើ មាននីតិជននិងអនីតិជន ទោសរបស់អនីតិជននឹងត្រូវបន្ថយពាក់កណ្តាល ធៀបនឹងទោសប្រកាសចំពោះនីតិជន។ ក្នុងករណីក្នុងសំណុំរឿងមានតែអនីតិជនតែម្នាក់ឯង តើរបៀបគិតដូចម្តេចទៅ។ អនីតិជន បន្ថែមពីលើការសម្រាលជាស្វ័យប្រវត្តិ នឹងទទួលការសម្រាលទោសបន្ថែមតាមមាត្រា១៦៤ ប្រសិនបើមានកត្តាស្ថានសម្រាល។ ករណីសម្រាលត្រួតដូចនេះ តើគេត្រូវអនុវត្តដូចម្តេច? បន្ថែមពីលើនេះ ក្នុងករណីអនីតិជន ពាក់ព័ន្ធបទល្មើសគ្រឿងញៀន តើគាត់នឹងទទួលទោសតាមច្បាប់ពិសេស (ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន)។ មកដល់ពេលនេះ តាមអ្វីដែលអ្នកនិពន្ធបានដឹង មិនទាន់មានការណែនាំ ឬបំភ្លឺក្នុងសាលដីកា ឬសាលក្រមណាមួយទេ។ សៀវភៅរបស់ក្រសួងយុត្តិធម៌ ហាក់ទំនង ចង្អុលឲ្យគិតគណនាតាមទោសដែលចែងក្នុងច្បាប់។ ឧទាហរណ៍ បទហិង្សាដោយចេតនា មានទោសពីមួយទៅបីឆ្នាំ។ បើអនុវត្តតាមមាត្រា១៦០(១) គឺទោសពី១ឆ្នាំទៅ ១ឆ្នាំកន្លះ (ពាក់កណ្តាល) ។ បើអនុវត្តតាមមាត្រា១៦៤(៤)អប្បបរមាធ្លាក់រហូតដល់១ថ្ងៃ។ ដូចនេះ ទោសដែលនឹងប្រកាសចុងក្រោយ <u>ត្រូវចន្លោះពី ១ថ្ងៃទៅដល់១ឆ្នាំកន្លះ។</u>

**៣**. ក្នុងសំណុំរឿងនេះ អ្វីដែលជាបញ្ហាគឺភាពមិនជាក់លាក់នៃធាតុផ្សំរវាង មនុស្សឃាតដោយចេតនាមាត្រា១៩៩ និងឃាតកម្មគិតទុកជាមុន (មាត្រា២០០)។ គម្លាតទោសខុសគ្នាពី១៥ឆ្នាំទៅមួយជីវិត ដែលគេត្រូវប្រយ័ត្នប្រយែងមែនទែនអំពីអង្គហេតុ និងភស្តុតាង បង្ហាញពីជាគម្រោង ឬការពួនស្ទាក់។ ពិសេសនិងសំខាន់ជាងនេះ គឺធាតុផ្សំអន្តនោម័ត គឺចេតនាសម្លាប់ធ្វើឲ្យស្លាប់។ ការពួនស្ទាក់វាយ អាចមិនមានបំណងដល់ស្លាប់ ក៏ប៉ុន្តែស្ថានភាពនៃជនរងគ្រោះ (ដែលជនជាប់ចោទមិនបានដឹង) អាចនាំឲ្យស្លាប់។ បើមិនមានចេតនាឲ្យស្លាប់ វាអាចនឹងជាបទមនុស្សឃាដដោយអចេតនា ឬហិង្សាដោយចេតនាមានស្ថានទម្ងន់ (ជនរងគ្រោះស្លាប់)។ រំពឹងថា សាលដីកានាពេលខាងមុខនឹងបំភ្លឺបញ្ហានេះ។

សម្រាប់សំណុំរឿងស្រដៀងគ្នាសូមមើល <u>សាលដីកាកំពូលលេខ៣៩៥</u> និង<u>ខ្លឹមសារសង្ខេប។</u>